ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៤៧២០ ឥកក

# សេចក្ដីសម្រេច
## ស្ដីពី
## របៀបរបបការងារ និងការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់ក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ ១ ៖** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់ក្រសួងមហាផ្ទៃ។

**ប្រការ ២ ៖** រដ្ឋមន្ត្រី ទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៣ ៖** ត្រូវបានបែងចែកប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការដើម្បីជួយរដ្ឋមន្ត្រី ដូចខាងក្រោម ៖

១. ឯកឧត្តម **សក់ សេដ្ឋា** ទទួលប្រចាំការ និងជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានរដ្ឋបាល

២. ឯកឧត្តម **តេង សាវង្ស** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គស្នងការដ្ឋាននគរបាលជាតិ

៣. ឯកឧត្តម **អ៊ុក គីមលេខ** ទទួលជួយរដ្ឋមន្ត្រី លើការងារផែនសណ្តាប់ធ្នាប់ និងសាធារណៈ

៤. ឯកឧត្តម **ប៉ាវ ហមផាន** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គនាយកដ្ឋានពន្ធនាគារ

៥. ឯកឧត្តម **ឌី ច័ន្ទផល** ទទួលជួយរដ្ឋមន្ត្រី លើការងារទំនាក់ទំនងនិងសហប្រតិបត្តិការអន្តរជាតិ ហើយជាអ្នកសិន និងកិច្ចការក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាន

៦. លោកជំទាវ **ជូ ប៊ុនអេង** ទទួលជួយរដ្ឋមន្ត្រី លើការងារប្រឆាំងការជួញដូរមនុស្ស និងយេនឌ័រ

៧. ឯកឧត្តម **ចាន់ អ៊ិន** ទទួលជួយរដ្ឋមន្ត្រី លើការងារបុគ្គលិកផ្នែកនគរបាលជាតិ បណ្ឌិត្យសភានគរបាលកម្ពុជា និងបណ្តុះបណ្តាលធនធានមនុស្ស

៨. ឯកឧត្តម **តៅ ឌុនដារ៉ា** ទទួលជួយរដ្ឋមន្ត្រី លើការងារពាក់ព័ន្ធជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគ ការងារស្លាបនា និងវិស្វកម្ម និងផ្នែកហិរញ្ញវត្ថុស៊ីវិល

៩. ឯកឧត្តម **ខៀវ សុភ័គ** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គលេខាធិការដ្ឋាន និងនាយកខុទ្ទកាល័យរដ្ឋមន្ត្រី

១០. ឯកឧត្តម **ម៉ៅ ម៉ុនណារិន** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ

១១. ឯកឧត្តម **ម៉ៅ ច័ន្ទតារា** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

១២. ឯកឧត្តម **សុខ ផល** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គនាយកដ្ឋានអន្តោប្រវេសន៍

១៣. ឯកឧត្តម **ម៉ុន ហុន** ទទួលជួយរដ្ឋមន្ត្រី លើការងារក្រុមប្រឹក្សានីតិកម្ម សមាគមនិងអង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយ

១៤. ឯកឧត្តម **ហ៊ុយ ចណ្ណះ** ទទួលជួយរដ្ឋមន្ត្រី លើការងារផ្សព្វផ្សាយអប់រំ និងវិស័យកីឡាក្រសួងមហាផ្ទៃ

១៥. ឯកឧត្តម **ម៉ៀច សុផាន់ណា** ទទួលជួយរដ្ឋមន្ត្រី លើការងារប្រឆាំងផលិតផលក្លែងក្លាយ

១៦. ឯកឧត្តម **អច មង្គល** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គាធិការដ្ឋាន

១៧. ឯកឧត្តម **ម៉ាន់ ចំរើន** ទទួលជួយរដ្ឋមន្ត្រី លើការងារលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

១៨. ឯកឧត្តម **ឆាំ ដា** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងច្បាប់អន្តរជាតិ ។

**ប្រការ ៤** ៖ ត្រូវបានបែងចែកប្រគល់ភារកិច្ចជូនអនុរដ្ឋលេខាធិការ ដូចខាងក្រោម ៖

១. ឯកឧត្តម **សំរិទ្ធ ឌី** ទទួលជួយរដ្ឋមន្ត្រីលើការងារផែននគរបាលព្រំដែន

២. ឯកឧត្តម អ៊ុង សាមី ឯកឧត្តម លូ រ៉ាមីន ឯកឧត្តម លេង វី ឯកឧត្តម អ៊ុំ ម៉ារ៉ា ឯកឧត្តម អ៊ិត សំអន ឯកឧត្តម កុល វីរក្ស ជួយកិច្ចការងារឯកឧត្តម **សក់ សេដ្ឋា**

៣. ឯកឧត្តម ស៊ាង ប៊ុនលាង ឯកឧត្តម សួន ឈាងលី ឯកឧត្តម មួន សារ៉េន ឯកឧត្តម សោម ច័ន្ទនីណា ជួយកិច្ចការងារឯកឧត្តម **តេង សាវង្ស**

៤. ឯកឧត្តម យុន ឈុន្នី ឯកឧត្តម សួស អង្គារ ជួយកិច្ចការងារឯកឧត្តម **អ៊ុក គីមលេខ**

៥. ឯកឧត្តម ហេង ហាក់ ជួយកិច្ចការងារឯកឧត្តម **ប៉ាវ ហាមផាន**

៦. ឯកឧត្តម ឡុង ផល ឯកឧត្តម ពឹម សំណាង ជួយកិច្ចការងារឯកឧត្តម **ឌី ច័ន្ទ្រផល**

៧. លោកជំទាវ ជួញ សុផៃ លោកជំទាវ ព្រំ ចន្ថា លោកជំទាវ អុង សុភារី ជួយកិច្ចការងារលោកជំទាវ **ង៉ូ ម៉ិនះអេង**

៨. លោកជំទាវ មៀង ស៊ាងសេង ជួយកិច្ចការងារឯកឧត្តម **ខៀវ សុភ័គ**

៩. ឯកឧត្តម ឯម សំណាង ជួយកិច្ចការងារឯកឧត្តម **ម៉ៅ ម៉ុនណារិន**

១០. ឯកឧត្តម ឌី សុកជាន ជួយកិច្ចការងារឯកឧត្តម **ម៉ៅ ច័ន្ទតារា**

១១. ឯកឧត្តម ប៉ុលី ដា ឯកឧត្តម ជាង ពៅ ជួយកិច្ចការងារឯកឧត្តម **សុខ ផល**

១២. ឯកឧត្តម ផុន ប៊ុនថាល់ ជួយកិច្ចការងារឯកឧត្តម **ម៉ុន ហុន**

១៣. ឯកឧត្តម ភឹម ជាតិ ជួយកិច្ចការងារឯកឧត្តម **ម៉ៀច សុផាន់ណា**

១៤. ឯកឧត្តម រស់ វុណ្ណា ជួយកិច្ចការងារឯកឧត្តម **អច មង្គល**

១៥. ឯកឧត្តម ឡាយ ណាវុធ ជួយកិច្ចការងារឯកឧត្តម **ម៉ាន់ ចំរើន**

១៦. ឯកឧត្តម សុខ សារឿន ជួយកិច្ចការងារឯកឧត្តម **ឡាំ ខា**

១៧. ឯកឧត្តម សុខ មុនី ជួយកិច្ចការងារឯកឧត្តម **សំរិទ្ធ ឌី ។**

**ប្រការ ៥ ៖** ក្រៅពីភារកិច្ចដូចបានចែងខាងលើ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ គ្រប់រូបត្រូវបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី ។

**ប្រការ ៦ ៖** រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មានមន្ត្រីជំនួយការ ដែលតែងតាំងដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមបទបញ្ញត្តិជាធរមាន។

**ប្រការ ៧ ៖** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២,៣,៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៨*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

***កន្លែងទទួល:***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សាលារាជធានី-ខេត្ត*
- *ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដើម្បីជូនជ្រាប*
- *ដូចប្រការ ២,៣,៤និង៧ ដើម្បីអនុវត្ត*
- *ឯកសារ-កាលប្បវត្តិ*